សម្រាប់ការចុះផ្សាយបន្ទាន់ ៖ ថ្ងៃសុក្រទី ២២ មេសា ២០២០
លេខទំនាក់ទំនងសាលាក្រុង 781-286-8111

# សារលិខិតរបស់សាលាក្រុងជុំវិញ COVID-19៖ ថ្ងៃទី ២២ មេសា ២០២០

## *ការធ្វើតេស្តរកមេរោគ COVID-19 មានផ្តល់ជូនដល់ប្រជាជនទាំងអស់ នៅ ៣ ទីតាំង*

ថ្ងៃទី ២២ មេសា ២០២០២ - ក្រុមឆ្លើយតបរហ័សប្រចាំក្រុង Revere នៅតែបន្តការងារយ៉ាងសកម្ម ដើម្បីកាត់បន្ថយល្បឿននៃការឆ្លង និងការរាលដាលនៃជំងឺ COVID-19។ ហើយបានរៀបចំវិធានការរួចជាស្រេចដើម្បីទប់ទល់នឹងការឆ្លងនានា។ នៅថ្ងៃនេះ នាយកដ្ឋានសុខាភិបាលរបស់រដ្ឋ Massachusetts បានផ្តល់ដំណឹងមកកាន់ក្រុមសុខាភិបាលប្រចាំក្រុង Revere ថា បានរកឃើញអ្នកឆ្លងមេរោគ COVID-19 សរុបចំនួន ៨០៥ ករណីនៅក្នុងក្រុង Revere។

នៅពេលនេះ ប្រជាជន Revere អាចធ្វើតេស្តរកមេរោគ COVID-19 បាន នៅទីតាំងចំនួន ៣ កន្លែង ដោយមិនតម្រូវឲ្យមានធានារ៉ាប់រង មិនចាំបាច់មាន PCP និងមិនត្រូវបានចោទសួរសំណួរផ្សេងៗនោះឡើយ។ ទីតាំងទាំងនោះ មានដូចជា៖

East Boston Neighborhood Health Center: បានប្រកាសឲ្យប្រជាជនធ្វើការដើរចូលពិនិត្យ(Walk-In) ឬបើកឡានចូលទៅពិនិត្យ (Drive-Thru) ដើម្បីស្វែងរកលទ្ធផលរោគ នៅ Suffolk Downs។ ទីតាំងនេះនឹងបើកជារៀងរាល់ថ្ងៃ សម្រាប់ប្រជាជន Revere រូបណា ដែលសង្ស័យថាខ្លួនមានជំងឺ។

Beth Israel Deaconess ដែលស្ថិតនៅ 1000 Broadway ក្នុងក្រុង Chelsea ក៏មានសេវាឲ្យដើរចូល ឬធ្វើការណាត់ទុកជាមុនដើម្បីពិនិត្យផងដែរ។

MGH Chelsea Healthcare ដែលស្ថិតនៅ 100 Everett Ave ក្នុងក្រុង Chelsea ក៏មានផ្តល់សេវាឲ្យដើរចូលពិនិត្យផងដែរ។ អ្នកអាចរកព័ត៌មានពីការធ្វើតេស្តផ្សេងៗទៀតនៅលើ mass.gov ជាមួយនឹងឯកសារជាច្រើនទាក់នឹងទីតាំងសម្រាប់ធ្វើតេស្ត។ ក្រុមការងារសាលាក្រុងកំពុងធ្វើការជាមួយក្រុមការងាររបស់រដ្ឋ អង្គភាពការពារជាតិ និងក្រុមសុខាភិបាលថ្នាក់តំបន់ ដើម្បីផ្តល់កម្មវិធី និងសេវាធ្វើតេស្តបន្ថែមទៀត នៅកន្លែងដែលមានមនុស្សចាស់រស់នៅ៕